**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ៖ ០០៨ ស.អ.យ.

*រាជធានីភ្នំពេញ*, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០

**សូមគោរពជូន**
**ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**កម្មវត្ថុ** : សំណើសុំកែសម្រួលការអនុវត្តន៍បើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជា និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈដែលកំពុងទទួលមុខតំណែងជាអ្នកនយោបាយ និងអ្នកនៅក្នុងបន្ទុក ។

**យោង** : អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ស្តីពីការកែសម្រួលការអនុវត្តន៍របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធបៀវត្សន៍ថ្មី

- អនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- តាមស្មារតីនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

អាស្រ័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មេត្តាជ្រាបថា យោងតាមខ្លឹមសារមាត្រា ៤ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ ។ ចំពោះប្រាក់សោធនប្រចាំខែរបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលកំពុងទទួលមុខតំណែងជាអ្នកនយោបាយមិនត្រូវបានបើកផ្តល់ជូនទេ ។ យោងតាមអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅក្នុងខ្លឹមសារមាត្រា ៥ បានអនុញ្ញាតឱ្យមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ នៅក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុញ្ញាតឱ្យបើកប្រាក់សោធនប្រចាំខែឡើងវិញ ការកំណត់នៃអនុក្រឹត្យនេះនៅខ្វះមន្ត្រីរាជការជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលបម្រើមុខងារនយោបាយ នៅក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីមុខងារនយោបាយនៅតាមក្រសួង ស្ថាប័នជាតិ មិនត្រូវបានអនុញ្ញាតអោយបើកប្រាក់សោធនប្រចាំខែជូនទេ ។

យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រីនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដើម្បីធានាការបើកប្រាក់សោធននេះ បានឯកភាពអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំសេចក្តីព្រាងអនុក្រឹត្យ ដើម្បីកែសម្រួលការបើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពាក់លី គ្រួសារជនមរណៈ ដែលបានទទួលតំណែងជាអ្នកនយោបាយនៅក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ខណ្ឌ ឃុំ សង្កាត់

និងគ្រប់ក្រសួង ស្ថាប័នជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។ ចំពោះប្រាក់សោធនប្រចាំខែ ដែលត្រូវបានផ្អាកក្នុងរយៈពេលកាន់មុខតំណែងជាអ្នកនយោបាយកន្លងមក មិនត្រូវបានគិតប្រាក់ជូនសមីជនវិញឡើយ ។

ក្រសួងសង្គម អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសេចក្ដីព្រាង អនុក្រឹត្យដូចដែលបានជូនភ្ជាប់មកជាមួយ ដើម្បីដាក់ឆ្លងសម្ដេចនាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មេត្តាពិនិត្យ និងសូមសេចក្ដីសម្រេចដ៏ខ្ពង់ខ្ពស់ពីសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដោយសេចក្ដីអនុគ្រោះ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**អ៊ិត~ សំហេង**